

# អារម្ភកថា

កូនសៀវភៅសំណួរចម្លើយនេះគឺជាជំនួយស្មារតីផ្តល់នូវចំណេះដឹងសម្រាប់ប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធទាំងអស់។

ខ្លឹមសារ សំណួរចម្លើយ បានដកស្រង់ចេញពី បទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ពាក់ព័ន្ធទៅនឹងដំណាក់កាលចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ ប្រសិនបើមិត្តអ្នកអានចង់ស្វែងយល់ ឬមានចម្ងល់ត្រង់ចំណុចណាមួយនៅក្នុងដំណាក់កាលទាំងបីខាងលើ មិត្តអ្នកអានអាចបើកមើលក្នុងកូនសៀវភៅនេះ ឬតាមគេហទំព័ររបស់ គ.ជ.ប (www.necelect.org.kh) ឬ ស្តាប់តាមវិទ្យុ FM ទាំង២៥ រាជធានី ខេត្ត នោះនឹងមានចម្លើយយ៉ាងក្បោះក្បាយពន្យល់ជូនបងប្អូន។

គ.ជ.ប មានសង្ឃឹមជឿជាក់យ៉ាងមុតមាំថា កូនសៀវភៅនេះនឹងផ្តល់នូវពុទ្ធិដល់មិត្តអ្នកអានទាក់ទង នឹងការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាពេលខាងមុខ។

ឆ្លៀតឱកាសនេះ គ.ជ.ប សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូតដែលបានជួយឧបត្ថម្ភគាំទ្រជាថវិកាដល់ការបោះពុម្ពផ្សាយកូនសៀវភៅនេះចំនួន ៦០.០០០ក្បាល សម្រាប់ចែកជូនដោយឥតគិតថ្លៃដល់មិត្តអ្នកអាន។

## សំណួរ ចម្លើយ ស្តីពី
## ការយល់ដឹងពីការបោះឆ្នោត
## ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧

### I.ដំណាក់កាលចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយ៖

**១.សំណួរ** : **តើការទទួលពាក្យ សុំចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់មានរយៈពេល ប៉ុន្មានថ្ងៃ? ចាប់ពីថ្ងៃណាដល់ថ្ងៃ ណា** ?

**ចម្លើយ** : ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេល ០៣ថ្ងៃ ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៧។

**២.សំណួរ** : **តើប្រជាពលរដ្ឋខ្មែរនៅមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានឬទេ** ?

**ចម្លើយ** : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិឈរឈ្មោះ ជាបេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានតែត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត

-ចេះអាន និងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត
- មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

**៣.សំណួរ** : **ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តើគណបក្សនយោបាយត្រូវធ្វើដូចម្តេច** ?

**ចម្លើយ** : ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតយ៉ាងតិច ៩០ (កៅសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ពាក្យសុំ ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

**៤.សំណួរ** : **តើពាក្យសុំចុះបញ្ជីបេក្ខជន ត្រូវភ្ជាប់មកជាមួយអ្វីខ្លះ**?

**ចម្លើយ** : ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយៈ

- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់
- អាសយដ្ឋាន នៃទីស្នាក់ការកណ្តាលគណបក្សនយាបាយ អាសយដ្ឋានទីស្នាក់ការគណបក្ស

នយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះ អ្នកតំណាង ប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ ដែលបានដាក់ស្នើបញ្ជីបេក្ខជន

- បញ្ជីរាយនាមបេក្ខជនចំនួន ០៧ ច្បាប់ ដែលមាន បេក្ខជន យ៉ាងហោចណាស់ស្មើនឹងពីរដង នៃចំនួន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- នាមត្រកូល និងនាមខ្លួនអាសយដ្ឋាន លិខិតបញ្ជាក់ ថា ពិតជាបានចុះឈ្មោះនិងមានឈ្មោះក្នុងបញ្ជី បោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណង ឈរឈ្មោះបោះឆ្នោត
- ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរ ឈ្មោះរបស់បេក្ខជនដែលបំពេញផ្ទាល់ដៃរបស់ បេក្ខជនម្នាក់ៗ និងរូបថតបេក្ខជនម្នាក់ៗ ចំនួន ០៣ (សន្លឹក) ទំហំ ៤ x ៦ ថតចំពីមុខ តាមគំរូរូប ថតធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។
- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរ កាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។

**៥.សំណួរ** : **តើមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពល ខេមរភូមិន្ទ នគរបាលជាតិ មានសិទ្ធិឈរឈ្មោះជា បេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានដែរឬទេ** ?

**ចម្លើយ** : មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ មានសិទ្ធិឈរឈ្មោះ ជាបេក្ខជនបោះ ឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់

បានតែត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ០៧(ប្រាំពីរ) ថ្ងៃមុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

**៦.សំណួរ** : **តើការបិទផ្សាយ ជាសាធារណៈនូវ បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះ នៅពេលណា បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន**?

**ចម្លើយ** : បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ០១ថ្ងៃ ។ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃ បន្ទាប់ ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន ដើម្បីឱ្យប្រជាពលរដ្ឋផ្តល់យោបល់បញ្ជីបេក្ខជន។ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំសង្កាត់មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជន នៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

**៧.សំណួរ** : **ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ បំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌ តើ**

**គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើដូចម្តេចខ្លះ** ?

**ចម្លើយ** : គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់ គណបក្សនយោបាយដែលបានស្នើសុំចុះបញ្ជីបេក្ខជននោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ ហើយផ្តល់ឱកាសឱ្យគណបក្សនយោបាយនោះធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតជូនដំណឹង។

**៨.សំណួរ** : **តើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើដូចម្តេច នៅពេលដែលគណបក្សនយោបាយធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានត្រឹមត្រូវនិងទាន់ពេលវេលារួចរាល់ហើយនោះ**?

**ចម្លើយ** : គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន ក្នុងរយៈពេល ០១ (មួយ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ ។

**៩.សំណួរ** : **តើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើដូចម្តេចក្នុងករណីគណបក្សនយោបាយដែលដាក់ពាក្យស្នើសុំចុះបញ្ជីបេក្ខជនមិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងទាន់ពេលវេលា**?

**ចម្លើយ** : ក្នុងករណីនេះគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត

ត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយនោះ។

**១០.សំណួរ :** **ប្រសិនបើគណបក្សនយោបាយដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីបេក្ខជនរួចហើយ តែត្រូវបានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបដិសេធ តើសាមីគណបក្ស ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីទទួលទម្រង់បែបបទបដិសេធ** ?

**ចម្លើយ :** បន្ទាប់ពីទទួលបានទម្រង់បែបបទបដិសេធ សាមីគណបក្ស ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៥(ប្រាំ) ថ្ងៃ។

**១១.សំណួរ :** **តើគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវដោះស្រាយ ប៉ុន្មានថ្ងៃ**?

**ចម្លើយ :** គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវដោះស្រាយក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ។

**១២.សំណួរ :** **តើគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតត្រូវធ្វើអ្វីខ្លះ ក្នុងករណីសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ារបស់សាមីគណបក្ស** ?

**ចម្លើយ :** ក្នុងករណីសម្រេចយល់ព្រមតាម ពាក្យបណ្តឹងតវ៉ា គណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតត្រូវបំពេញសម្រង់សេចក្តីសម្រេចយល់ព្រម (ទ.១២០៣) ចំនួន ០៤

(បួន) ច្បាប់ ដោយបញ្ជាក់ពីមូលហេតុយល់ព្រមឱ្យបានច្បាស់លាស់។

**១៣.សំណួរ :** **បន្ទាប់ពីទទួលបាន សម្រង់សេចក្ដីសម្រេចយល់ព្រម ដោយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើដូចម្ដេចលើពាក្យសុំចុះបញ្ជីបេក្ខជននៃ គណបក្សនយោបាយនោះ ?**

**ចម្លើយ :** បន្ទាប់ពីទទួលបានសម្រង់សេចក្ដីសម្រេច យល់ព្រមដោយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្ដល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន នៃគណបក្សនយោបាយនោះដោយត្រូវបំពេញ លើពាក្យសុំចុះបញ្ជីបេក្ខជន (ទ.១០០៨) ទាំង ០២ (ពីរ) ច្បាប់ ចុះហត្ថលេខាកាលបរិច្ឆេទ និងបោះត្រាចូលជូនទៅសាមីគណបក្សនយោបាយ ០១ (មួយ) ច្បាប់ និងរក្សាទុក ០១ (មួយ) ច្បាប់។

**១៤.សំណួរ :** **ក្នុងករណីសម្រេចបដិសេធលើ ពាក្យបណ្ដឹង តវ៉ាលើគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតត្រូវធ្វើដូចម្ដេចខ្លះ?**

**ចម្លើយ :** ក្នុងករណីសម្រេចបដិសេធលើបណ្ដឹងតវ៉ាគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ត្រូវបំពេញសម្រង់សេចក្ដីសម្រេចបដិសេធ (ទ.១២០៣) ជា ០៤ (បួន) ច្បាប់ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបាន

ច្បាស់លាស់ ។

**១៥.សំណួរ:** **ប្រសិនបើគណបក្សនយោបាយដែលបានស្នើសុំចុះបញ្ជីបេក្ខជន ហើយត្រូវបានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតបដិសេធ តើសាមីគណបក្ស ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីទទួលទម្រង់បែបបទបដិសេធនោះ** ?

**ចម្លើយ** : បន្ទាប់ពីទទួលបាន ទម្រង់បែបបទ បដិសេធ សាមីគណបក្ស ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ។

**១៦.សំណួរ:** **ក្នុងករណីបដិសេធឬយល់ព្រមលើពាក្យបណ្តឹងតវ៉ា តើគ.ជ.ប ត្រូវបំពេញសម្រង់សេចក្តីសម្រេចដូចម្តេច** ?

**ចម្លើយ** : ក្នុងករណីបដិសេធ ឬយល់ព្រមលើពាក្យបណ្តឹងតវ៉ា គ.ជ.ប ត្រូវបំពេញសម្រង់សេចក្តីសម្រេចបដិសេធ ឬយល់ព្រមលើ (ទ.១២០៣) ចំនួន ០៤ (បួន) ច្បាប់រួចផ្ញើជូន៖

- អ្នកប្តឹងតវ៉ា ០១ (មួយ) ច្បាប់
- គធ.ខប ពាក់ព័ន្ធ ០១ (មួយ) ច្បាប់
- គឃ.សប ០១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ០១ (មួយ) ច្បាប់

ត្រូវផ្តល់ដំណឹងដល់គណបក្សនយោបាយដែលដាក់ពាក្យបណ្តឹងតវ៉ា ឬតំណាងថាសេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

**១៧.សំណួរ :** **តើប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត នៅក្នុងឃុំ សង្កាត់ មានសិទ្ធិប្តឹងជំទាស់ អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង បន្ទាប់ពីបិទផ្សាយជាសាធារណៈដែរឬទេ** ?

**ចម្លើយ :** បន្ទាប់ពីការបិទផ្សាយបញ្ជីបេក្ខជនដំបូងជាសាធារណៈ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជី បេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ។

**១៨.សំណួរ:** **ក្រោយពីបានទទួលពាក្យបណ្តឹងជំទាស់ តើគ.ជ.បត្រូវបើកសវនាការជាសាធារណៈក្នុង រយៈពេលប៉ុន្មានថ្ងៃ** ?

**ចម្លើយ :** គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹងជំទាស់។ គ.ជ.ប ត្រូវផ្តល់ព័ត៌មានដល់គណបក្សនយោបាយពាក់ព័ន្ធ និងផ្តល់ព័ត៌មានដល់អ្នកប្តឹងជំទាស់ ឬតំណាងនិងផ្សព្វផ្សាយជាសាធារណៈ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការ ។

**១៩.សំណួរ :** **ក្នុងករណីយល់ព្រម ឬបដិសេធលើបណ្តឹងជំទាស់ តើ គ.ជ.ប ត្រូវធ្វើ ដូចម្តេចខ្លះ?**

**ចម្លើយ :** គ.ជ.បត្រូវបំពេញសម្រង់សេចក្តីសម្រេច(ទ.១២០៣) ជា ០៥ (ប្រាំ) ច្បាប់ រួចផ្ញើជូនៈ

- អ្នកប្តឹងជំទាស់ ០១ (មួយ) ច្បាប់
- គណបក្សនយោបាយត្រូវគេប្តឹងជំទាស់ ០១ (មួយ) ច្បាប់
- គធ.ខប ពាក់ព័ន្ធ ០១ (មួយ) ច្បាប់
- គឃ.សប ពាក់ព័ន្ធ ០១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ០១ (មួយ) ច្បាប់

ត្រូវផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ និងសាមីគណបក្សនយោបាយ ថាសេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

**២០.សំណួរ :** **តើ គឃ.សប ត្រូវធ្វើដូចម្តេច ករណីបណ្តឹងជំទាស់ ត្រូវបានយល់ព្រមដោយ គ.ជ.ប ?**

**ចម្លើយ :** គឃ.សប ត្រូវបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជន នៃគណបក្សនយោបាយ ដែលមានការប្តឹងជំទាស់នោះ រួចហើយលុបបេក្ខភាពឬបញ្ជី បេក្ខជននោះចេញព្រមទាំងដកហូត និងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ។

**២១.សំណួរ :** **ប្រសិនបើគ្មានបណ្តឹងជំទាស់ តើបញ្ជីបេក្ខជនដំបូងអាចក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការបានដែរឬទេ?**

**ចម្លើយ** : បញ្ជីបេក្ខជនដំបូងនឹងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ប្រសិនបើគ្មានបណ្តឹងជំទាស់មកលើបញ្ជីនេះ ។

**២២.សំណួរ** : **តើលំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត រៀបចំយ៉ាងដូចម្តេច?**

**ចម្លើយ** : ផ្អែកលើបញ្ជីបេក្ខជនផ្លូវការ គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

**២៣.សំណួរ** : **តើរបៀបវារៈនៃពិធីចាប់ឆ្នោតកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត រៀបចំយ៉ាងដូចម្តេច?**

**ចម្លើយ** : របៀបវារៈនៃការចាប់ឆ្នោតមាន៖

- -សុន្ទរកថាបើកពិធី ថ្លែងដោយ ប្រធាន គឃ.សប
- -ការបង្ហាញសន្លឹកឆ្នោត សម្រាប់ចាប់ឆ្នោត និងស្រោមសំបុត្រ
- -ការចាប់ឆ្នោតធ្វើដោយ ព្រះសង្ឃ ឬ ឥស្សរជនចូលនិវត្តន៍ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបាន ពីគ្រប់គណបក្សនយោបាយ
- -ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត
- -ការបិទពិធីចាប់ឆ្នោត។

**២៤.សំណួរ** : **តើ គឃ.សប ត្រូវរៀបចំក្រដាសសន្លឹកឆ្នោតសម្រាប់គណបក្សនយោបាយនីមួយៗ ដូចម្តេច?**

**ចម្លើយ** : គឃ.សប ត្រូវរៀបចំក្រដាសសន្លឹកឆ្នោត សម្រាប់គណ

បក្សនយោបាយនីមួយៗដូចតទៅ៖

១.ក្រដាសសនេះមានប្រភេទដូចគ្នា និងទំហំប៉ុនគ្នា

២.ត្រូវសរសេរឈ្មោះគណបក្សជាអក្សរដែលមានពណ៌ និងប្រភេទតួអក្សរដូចគ្នានិងមានទំហំប៉ុនគ្នានៅលើក្រដាសសនេះ

៣.ក្រដាសដែលសរសេរឈ្មោះគណបក្សនយោបាយនីមួយៗរួចហើយត្រូវក្លាយជាសន្លឹកឆ្នោតរបស់គណបក្សដែលនឹងត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រដែលមានទំហំប៉ុនគ្នានិងពណ៌ដូចគ្នា ។

**២៥.សំណួរ** : **តើមុនចាប់ផ្តើមការចាប់ឆ្នោតគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើដូចម្តេចខ្លះ** ?

**ចម្លើយ** : មុនចាប់ផ្តើមការចាប់ឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនីមួយៗនៅចំពោះមុខអង្គពិធីមុននឹងបត់ដាក់ចូល និងបិតភ្ជិតស្រោមសំបុត្រតាមរបៀបដូចជា៖

១.សន្លឹកឆ្នោតនីមួយៗត្រូវបត់ជា ០២ (ពីរ) ផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិតរួចម្សៅ និងចងកៅស៊ូកងពណ៌ដូចគ្នា ។

២.ស្រោមសំបុត្រឆ្នោតទាំងអស់ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងប្រអប់ ឬឡាំងតែមួយ ហើយត្រូវក្រឡុកប្រអប់ ឬឡាំងឆ្នោតនោះ ។

៣.បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលត្រូវបានជ្រើស

ម្តងមួយៗ ពីប្រអប់ ឬឡាំងឆ្នោត ។

៤.ស្រោមសំបុត្រឆ្នោតដែលចាប់បាន ត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោម ០២ (ពីរ) នាក់ដែលជាសមាជិក គឃ.សប ។

៥.មន្ត្រី គឃ.សប ០១ (មួយ) នាក់ ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនៅចំពោះមុខអង្គពិធីហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទី២ ។

៦.មន្ត្រីទី២ ត្រូវអានឈ្មោះគណបក្សនយោបាយដែលសរសេរនៅលើសន្លឹកឆ្នោត និងសរសេរ លេខរៀង "លេខ១" នៅលើសន្លឹកឆ្នោតនោះហើយត្រូវបន្តធ្វើការចាប់ឆ្នោត និងចុះលេខរៀងតាមលំដាប់រហូតដល់សន្លឹកឆ្នោតចុងក្រោយ ។

លេខាធិការនៃ គឃ.សប ត្រូវបំពេញកំណត់ហេតុនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀង បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត(ទ.១១២១) ឱ្យបានរួចរាល់ ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងហើយ។តំណាងគណបក្សនយោបាយអាចចូលរួម ចុះហត្ថលេខាលើកំណត់ ហេតុនេះបាន ។

**២៦.សំណួរ** : **បន្ទាប់មក តើគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើអ្វីទៀត**?

កំណត់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោតតាមលទ្ធផលនៃការចាប់ឆ្នោតជា ០៤ (បួន) ច្បាប់ដើម្បីផ្ញើជូន៖

- គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ០១ ច្បាប់
- គធ.ខប ០១ ច្បាប់
- រក្សាទុកជាឯកសារ ០១ ច្បាប់
- បិទផ្សាយ ០១ ច្បាប់

គឃ.សប ត្រូវធ្វើរបាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុ ដើម្បីផ្ញើជូនទៅ គ.ជ.ប តាមរយៈ គធ.ខប ។

**២៧.សំណួរ: តើការធ្វើគំរូនិងបោះពុម្ពសន្លឹកឆ្នោត សម្រាប់ឃុំសង្កាត់នីមួយៗយ៉ាងដូចម្តេចដែរ ?**

**ចម្លើយ :** គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ឃុំសង្កាត់នីមួយៗដូចតទៅ៖

- ការបោះពុម្ពសន្លឹកឆ្នោតត្រូវផ្អែកតាមចំនួនគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនផ្លូវការនៅក្នុងឃុំសង្កាត់នោះ។ សន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់ ណាប្រើប្រាស់បានតែនៅក្នុងឃុំ សង្កាត់ នោះតែប៉ុណ្ណោះ ។
- ឈ្មោះ រូបសញ្ញាគណបក្សនយោបាយនៅលើសន្លឹកឆ្នោតត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀងតាមលទ្ធផលនៃការចាប់ឆ្នោត ។

II.**ដំណាក់កាលយុទ្ធនាការឃោសនាបោះឆ្នោត**

**២៨.សំណួរ:** **តើគោលបំណងនៃការឃោសនាបោះឆ្នោតដើម្បីអ្វី**?

**ចម្លើយ** : ការឃោសនាបោះឆ្នោត មានបំណងឱ្យគណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ដល់អ្នកបោះឆ្នោត។

**២៩.សំណួរ** : **តើអ្វីទៅដែល ហៅថាការឃោសនាបោះឆ្នោត**?

**ចម្លើយ** : ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬ គណបក្សនយោបាយណាមួយ។

**៣០.សំណួរ** : **តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកជាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ** ?

**ចម្លើយ** : សកម្មភាព ដែលចាត់ទុកជាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយរួមមាន៖ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយ យាន ជំនិះ គ្រប់ប្រភេទ ការជួបជុំ ឬការឃោសនាតាមផ្ទះ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ការផ្សព្វផ្សាយតាមរលកធាតុអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬចាក់ផ្សាយកាស្សែតវីដេអូ ឬ

វីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូ ឬទីសាធារណៈ សកម្មភាពបិទផ្សាយនូវ បដា ពាក្យស្លោក ឬកម្មវិធីនយោបាយ សកម្មភាពចែកចាយខិត្តប័ណ្ណ គណបក្សនយោបាយ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗ ការប្រគំតន្ត្រី និងការរៀបចំកម្មវិធីប្រកួតកីឡាជាដើម ។

**៣១.សំណួរ:** **តើការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ មានរយៈពេលប៉ុន្មានថ្ងៃ** ?

**ចម្លើយ** : ការឃោសនាបោះឆ្នោត ត្រូវមានរយៈ ពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតត្រូវ ដំណើរការ ក្នុងរយៈពេល ១៤ (ដប់បួន )ថ្ងៃ ហើយគ្រប់ សកម្មភាពនៃការឃោសនាត្រូវបញ្ឈប់ ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

**៣២. សំណួរ :** **តើគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅឃោសនាបោះឆ្នោត នៅទីសាធារណៈបានដែរឬទេ**?

**ចម្លើយ** : ស្លាកសញ្ញាគណបក្សនយោបាយ និង ឯកសារ ឃោសនាបោះឆ្នោត អាចលើក ឬបិទនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំសង្កាត់ ផ្អែក លើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង សោភ័ណភាពសាធារណៈ។ ស្លាកសញ្ញា និង សម្ភារ

ឃោសនាគណបក្សនយោបាយ មិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬ ការិយាល័យរបស់រដ្ឋ ។

**៣៣. សំណួរ :** **តើគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅឃោសនា បោះឆ្នោត នៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋបានដែរឬទេ**?

**ចម្លើយ** : ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនារូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណ នៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាឃោសនារូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណរបស់គណបក្សនយោបាយណាមួយបាន។

**៣៤.សំណួរ :** **តើការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោតចាត់ទុកជាសកម្មភាពឃោសនាបោះឆ្នោតដែរឬទេ**?

**ចម្លើយ** : ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធ

នឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៣៥.សំណួរ : **តើការស្លៀកពាក់ (សម្លៀកបំពាក់-មួក)ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់អាចចាត់ទុកថា ជាការឃោសនាឬទេ** ?

ចម្លើយ : ការស្លៀកសម្លៀកបំពាក់ ឬពាក់មួកដែលតាំងបង្ហាញឱ្យឃើញនូវសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់មិនរួមបញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតឡើយ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

៣៦.សំណួរ : **តើគណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរ ដោយក្រុមថ្មើរជើង ឬ ដោយយានជំនិះគ្រប់ប្រភេទ ក្នុងឃុំ សង្កាត់ បានប៉ុន្មានដងក្នុងអំឡុងពេលឃោសនាបោះឆ្នោត**?

ចម្លើយ : គណបក្សនយោបាយ អាចហែក្បួន ព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងច្រើន ០២ (ពីរ) ដង នៅក្នុងឃុំសង្កាត់ ដែលគណបក្សមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

**៣៧. សំណួរ :** **តើមន្ត្រីរាជការស៊ីវិលអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ហាមធ្វើសកម្មភាពអ្វីខ្លះក្នុងអំឡុងពេលឃោសនាបោះឆ្នោត** ?

**ចម្លើយ :** ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា៧២ ចែងថាមន្ត្រីរាជការស៊ីវិលអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ៖

- មិនត្រូវប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោលឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិតរូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ខាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ
- មិនត្រូវប្រើប្រាស់អគារឬការិយាល័យរបស់រដ្ឋដើម្បីឃោសនាបោះឆ្នោតស្វែងរកសំឡេងឆ្នោត ឱ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ
- មិនត្រូវចូលរួមសកម្ម ក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ។

**៣៨.សំណួរ :** **តើមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ**

**និង មន្ត្រីតុលាការ បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះ គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់បានឬទេ** ?

**ចម្លើយ** : ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានចែងថាមន្ត្រីរាជការស៊ីវិល អាជ្ញាធរ ដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងធ្វើការ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ប៉ុន្តែះ

- មិនត្រូវស្លៀកពាក់ឯកសណ្ឋាន
- មិនត្រូវមានអាវុធជាប់នឹងខ្លួន
- មិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

**៣៩.សំណួរ** : **តើក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោតគណបក្សនយោបាយ បេក្ខជន និងអ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធានបទប្បញ្ញត្តិ និងប្រកាន់អាកប្បកិរិយា យ៉ាងដូចម្តេច** ?

**ចម្លើយ** : ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ៧៦ បានចែងថាក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់

បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ត្រូវតែគោរពតាមវិធានបទប្បញ្ញត្តិនិងគោលការណ៍ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រមសីលធម៌ គោរពតាម បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា។ របៀបបែបបទប្តឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹងត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

៤០.**សំណួរ** : **តើអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរដូចម្តេច និងហាមមិនឱ្យធ្វើសកម្មភាពអ្វីខ្លះ** ?

**ចម្លើយ** : អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនត្រូវធ្វើសកម្មភាពណាមួយទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដូចជាៈ ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនា ឬចេញសេចក្តី

ថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយ ក្នុងគោលបំណង គាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំង ឬការផ្តល់មធ្យោបាយជាថវិកា សម្ភារបរិក្ខារធនធានមនុស្ស ឬមធ្យោបាយផ្សេងៗដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**៤១.សំណួរ** : **តើអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា មានទោសដែរឬទេ ប្រសិនបើមានជំហរមិនអព្យាក្រឹតក្នុងដំណាក់កាលឃោសនាបោះឆ្នោត** ?

**ចម្លើយ** : ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ១៩៧ បានចែងថា ត្រូវផាកពិន័យជាប្រាក់ពី ១០,០០០,០០០៛ (ដប់លាន) រៀល ទៅ ២០,០០០,០០០៛ (ម្ភៃលាន) រៀល ដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុកនិងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា៧៤ នៃច្បាប់នេះ ។ ការទទួលខុសត្រូវខាងលើមិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដែលខាងលើ ឬបទល្មើសផ្សេងទៀត ដែលបានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

៤២.សំណួរ : **តើជនបរទេសដែលមានវត្តមានក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬជនណាម្នាក់ មានទោសដែរឬទេ**?

**ចម្លើយ** : ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ១៨០ ត្រូវផាកពិន័យជាប្រាក់ពី ៥,០០០,០០០៛ (ប្រាំលាន) រៀល ទៅ ១០,០០០,០០០៛ (ដប់លាន) រៀល ដោយ គ.ជ.ប ចំពោះជនបរទេស ដែលមានវត្តមានក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬជនណាម្នាក់។ ហើយជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទ ដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍ ។

៤៣.សំណួរ : **តើការប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធ ក្រុមជាតិពូជសាសន៍ ឬនៃសាសនាណាមួយ ជាកំណត់នៅក្នុងការឃោសនាបោះឆ្នោត និងពេលបោះឆ្នោត មានទោសដែរឬទេ**?

**ចម្លើយ** : ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ១៨១ បានចែងថា ការប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិក នៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងការឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ត្រូវផាកពិន័យជាប្រាក់ពី ៥,០០០,០០០៛ (ប្រាំលាន) រៀល ទៅ ១០,០០០,០០០៛ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយ គ.ជ.ប ដោយពុំទាន់គិតទោសព្រហ្មទណ្ឌផ្សេងៗទៀត។ ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គ.ជ.ប ត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ដែលក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**៤៤. សំណួរ** : **តើគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុង មាត្រា ១៨១ នៃច្បាប់មានទោសដែរឬទេ** ?

**ចម្លើយ** : ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ១៨២ ត្រូវផាកពិន័យ ជាប្រាក់ពី ១០,០០០,០០០៛ (ដប់លាន) រៀល ទៅ ៣០,០០០,០០០៛ (សាមសិប

លាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយ គ.ជ.ប ដោយពុំទាន់គិតទោសទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា ១៨១ ខាងលើនេះ។

**៤៥. សំណួរ :** **ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា៧០ នៃច្បាប់ តើត្រូវមានទោសដូចម្តេច ?**

**ចម្លើយ :** តាមច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ១៨៩ បានចែងថា ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយ គ.ជ.ប ចំពោះជនដែលប្រព្រឹត្តល្មើស និងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា៧០ នៃច្បាប់នេះ។ ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥,០០០,០០០៛ (ប្រាំលាន) រៀល ទៅ ១០,០០០,០០០៛ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**៤៦. សំណួរ :** **តើគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស មាត្រា ១៨៤ នៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានទោសដែរឬទេ ?**

**ចម្លើយ** : ប្រសិនបើមានករណីនេះ ត្រូវផាកពិន័យជាប្រាក់ពី ១០,០០០,០០០៛ (ដប់លាន) រៀល ទៅ ២០,០០០,០០០៛ (ម្ភៃលាន) រៀល /និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយ គ.ជ.ប (មាត្រា ១៨៥ នៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់)។

៤៧. **សំណួរ** : **តើអ្នកដែលប្រើប្រាស់សម្ភារៈមធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សណាមួយ ឬបេក្ខជនណាមួយមានទោសដែរឬទេ** ?

**ចម្លើយ** : តាមច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ១៨៦ បានចែងថា ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយ គ.ជ.ប ចំពោះជនណាដែលប្រើប្រាស់សម្ភារមធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សណាមួយ ឬ បេក្ខជនណាមួយ។ ក្នុងករណីនៅតែមិនគោរពតាមការព្រមានខាងលើត្រូវផាកពិន័យជាប្រាក់ពី ៥,០០០,០០០៛ (ប្រាំលាន) រៀល ទៅ ១០,០០០,០០០៛ (ដប់លាន) រៀល ដោយ គ.ជ.ប ។

## III .**ដំណាក់កាលបោះឆ្នោត**

៤៨.**សំណួរ** : **តើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ប្រព្រឹត្តទៅនៅពេលណា? ចាប់ពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន** ?

**ចម្លើយ** : ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ០៧:០០ព្រឹក ដល់ម៉ោង ០៣:០០រសៀល ។

**៤៩.សំណួរ** : **តើធ្វើដូចម្តេច ដើម្បីដឹងថាការិយាល័យបោះឆ្នោតនៅទីកន្លែងណាខ្លះ** ?

**ចម្លើយ** : លោកអ្នកកុំបារម្ភ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ គ.ជ.ប នឹងធ្វើការបិទផ្សាយបញ្ជីឈ្មោះ ទីតាំងការិយាល័យបោះឆ្នោតនៅគ្រប់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

**៥០.សំណួរ** : **តើប្រជាពលរដ្ឋត្រូវធ្វើអ្វីខ្លះមុនថ្ងៃបោះឆ្នោត** ?

**ចម្លើយ** : ប្រជាពលរដ្ឋទាំងអស់ត្រូវស្គាល់ទីតាំងការិយាល័យ បោះឆ្នោត លេខកូដការិយាល័យបោះឆ្នោត និងលេខ រៀងឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតឱ្យបានច្បាស់។

**៥១.សំណួរ** : **តើប្រជាពលរដ្ឋទាំងអស់មានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតបានដែរ ឬទេ** ?

**ចម្លើយ** : អ្នកដែលមានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតបាន លុះត្រាតែជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយជននោះមិនទាន់បានបោះឆ្នោតនៅឡើយ។

**៥២. សំណួរ**: **តើមានឯកសារអ្វីខ្លះ ដែលត្រូវប្រើប្រាស់នៅពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**?

**ចម្លើយ** : ឯកសារដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាន៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរណាមួយក្នុងចំណោមប្រភេទទាំង៣ ឬ
- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ។

**៥៣.សំណួរ: តើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត អាចយកទៅប្រើប្រាស់ក្នុងការបោះឆ្នោតបានដែរ ឬទេ?**

**ចម្លើយ** : ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត មិនអាចយកទៅប្រើប្រាស់ក្នុងការបោះឆ្នោតបានទេ។

**៥៤.សំណួរ : មានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ ប៉ុន្តែពុំទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរខូច ឬបាត់ តើត្រូវធ្វើដូចម្តេចដើម្បីបោះឆ្នោតបាន ?**

**ចម្លើយ** : ប្រសិនបើមានករណីដូចខាងលើនេះ សូមអញ្ជើញទៅស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដោយនាំយកទៅជាមួយនូវរូបថត៣x៤ ចំនួន៣សន្លឹក (ថតចំពីមុខ) និងសាក្សី២រូប ដែលមានសិទ្ធិបោះឆ្នោត និងមានទីលំនៅ ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយ ។

**៥៥.សំណួរ : តើកាលបរិច្ឆេទនៃការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត កំណត់ពីពេលណាដល់ពេលណា ?**

**ចម្លើយ** : ក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទី០៤ ខែឧសភា រហូតដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧ ។

**៥៦.សំណួរ** : **តើបញ្ជីព័ត៌មានអ្នកបោះឆ្នោតមានប្រយោជន៍យ៉ាងដូចម្តេច** ?

**ចម្លើយ** : បញ្ជីព័ត៌មាននេះមានប្រយោជន៍ណាស់ចំពោះប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ព្រោះបញ្ជីនេះបានផ្តល់ព័ត៌មានពីទីតាំង និងលេខកូដការិយាល័យបោះឆ្នោត លេខរៀង ឈ្មោះអ្នកបោះឆ្នោត កាលបរិច្ឆេទនៃថ្ងៃបោះឆ្នោតជាដើម ។

**៥៧.សំណួរ** : **តើការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតផ្លូវការធ្វើនៅពេលណា**?

**ចម្លើយ** : បញ្ជីទាំង០២មុខនេះ បិទផ្សាយនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ នៅការិយាល័យបោះឆ្នោត ។

**៥៨.សំណួរ** : **សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ តើមានបញ្ជីបោះឆ្នោតប៉ុន្មាន**? **សម្រាប់ធ្វើអ្វីខ្លះ**?

**ចម្លើយ** : សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ មានបញ្ជីបោះឆ្នោតចំនួន ២ច្បាប់ គឺមួយច្បាប់បិទនៅមុខការិយាល័យបោះឆ្នោត និងមួយច្បាប់ទៀត សម្រាប់ប្រើក្នុងពេលបោះឆ្នោត។

**៥៩.សំណួរ** : **តើសម្ភារបោះឆ្នោតសំខាន់ៗ សម្រាប់បម្រើឱ្យការបើកការិយាល័យបោះឆ្នោតមានអ្វីខ្លះ** ?

**ចម្លើយ** : សម្ភារបោះឆ្នោតសំខាន់ៗ បើខ្វះហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោតរួមមាន៖

- សន្លឹកឆ្នោតមិនទាន់ប្រើ
- គ្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត
- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ
- ហិបឆ្នោតនិងសោឃ្លុំមានលេខ
- ទឹកខ្មៅលុបមិនជ្រះ សម្រាប់ជ្រលក់ម្រាមដៃ និងសម្ភារមួយចំនួនទៀត។

**៦០.សំណួរ** : **នៅក្នុងការិយាល័យបោះឆ្នោត តើអ្នកសង្កេតការណ៍និងភ្នាក់ងារគណបក្សនយោបាយ អាចអង្គុយ ឬឈរនៅកន្លែងណាខ្លះ** ?

**ចម្លើយ** : នៅក្នុងការិយាល័យបោះឆ្នោត អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយអាចអង្គុយឬឈរ នៅខាងឆ្វេងដៃ ប្រធាន គ.ក.ប និងពីក្រោយតុលេខាធិការ និងអនុប្រធាន គ.ក.ប ។

**៦១.សំណួរ** : **តើការបោះឆ្នោតដោយសម្ងាត់មានន័យដូចម្តេច** ?

**ចម្លើយ** : លោកអ្នកគូសនៅលើសន្លឹកឆ្នោតដើម្បីជ្រើសរើសយកគណបក្សនយោបាយណាមួយដែលពេញចិត្តនៅក្នុងបន្ទប់សម្ងាត់។ ដូច្នេះមិនអាចមាននរណាម្នាក់ឃើញនិងដឹងបានឡើយ ។

**៦២.សំណួរ** : **តើអ្នកបោះឆ្នោតទទួលការណែនាំដូចម្តេចមុនពេលចូលទៅបន្ទប់សម្ងាត់**?

**ចម្លើយ** : មុនពេលលោកអ្នកទទួល បានសន្លឹកឆ្នោត អនុប្រធាន

គ.ក.ប នឹងណែនាំដោយសង្ខេបចំពោះអ្នកបោះឆ្នោត ដូចខាងក្រោម៖

- នេះគឺជាសន្លឹកឆ្នោត
- អ្នកត្រូវដើរទៅបន្ទប់សម្ងាត់ ប្រើប៊ិចដែលមាននៅទីនោះស្រាប់ ឬប៊ិចផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) អ្នកត្រូវគូសសញ្ញាគាំទ្រ នៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយ តែមួយគត់ដែលអ្នកពេញចិត្ត។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់មុននឹងគូស
- មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលអ្នកបានគូសស្ថិតនៅក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។

**៦៣.សំណួរ:** **នៅថ្ងៃបោះឆ្នោត តើមានការរៀបចំសណ្តាប់ធ្នាប់ ដើម្បីឱ្យអ្នកបោះឆ្នោត ងាយស្រួលក្នុងការបោះឆ្នោតដែរឬទេ** ?

**ចម្លើយ** : ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺ ជនពិការត្រូវបានផ្តល់អាទិភាពចូលបោះឆ្នោតមុន។ រីឯអ្នកបោះឆ្នោតផ្សេងៗទៀត មន្ត្រីនៃការិយាល័យបោះឆ្នោតនឹងអញ្ជើញឱ្យតម្រង់ជួរតាមលំដាប់មុនក្រោយ។

**៦៤. សំណួរ** : **តើមានវិធីណា ដែលអាចជួយឱ្យជនពិការបោះឆ្នោតបាន** ?

**ចម្លើយ** : ចំពោះជនពិការដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបានគាត់មានសិទ្ធិជ្រើសរើសអ្នកជំនួយ ម្នាក់ជានីតិជន

ទៅជាមួយ ឬមានសិទ្ធិស្នើសុំជំនួយពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតដើម្បីជួយគាត់ក្នុងការបោះឆ្នោត។

**៦៥. សំណួរ :** **តើជនប្រើមធ្យោបាយទុច្ចរិតនៅពេលបោះឆ្នោតមានទោសដែរឬទេ ?**

**ចម្លើយ :** មាត្រា ១៧១ នៃច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានចែងថា ត្រូវផាកពិន័យជាប្រាក់ពី ៥,០០០,០០០៛ (ប្រាំលាន) រៀល ទៅ ២០,០០០,០០០៛ (ម្ភៃលាន) រៀល ដោយ គ.ជ.ប ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលប្រើគ្រប់មធ្យោបាយទុច្ចរិត :

- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហឹង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត
- ធ្វើឱ្យមានការភ័ន្តច្រឡំ នាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតនិងរាប់សន្លឹកឆ្នោតបាន
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត

- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស ។
ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយ គ.ជ.ប បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**៦៦.សំណួរ** : **តើអ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតបានប៉ុន្មានសន្លឹក និងបានប៉ុន្មានដង** ?

**ចម្លើយ** : បានតែមួយសន្លឹក និងបានម្តងគត់ ។

**៦៧.សំណួរ** : **តើអ្នកបោះឆ្នោតអាចពាក់អាវ ឬអ្នកដែលមានស្លាកសញ្ញាគណបក្សនយោបាយចូលក្នុងការិយាល័យ បោះឆ្នោតបានដែរឬទេ** ?

**ចម្លើយ** : ហាមការស្លៀកពាក់ ឬដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

**ក្នុងករណីមានចម្ងល់**
**សូមទំនាក់ទំនងដើម្បីសួរព័ត៌មានបន្ថែម ៖**
**មកកាន់គ្រូបង្គោល គ.ជ.ប សម្រាប់ឆ្លើយផ្ទាល់ ៖**

១-លោក **មុំ សុទ្ធ** ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
ទូរស័ព្ទលេខ ៖ ០១២ ៩៧ ៣៩ ៣៧

២-លោក **សាត់ សុវណ្ណា** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
ទូរស័ព្ទលេខ ៖ ០១២ ៩១ ៥១ ៨១

៣-លោក **ស៊ុំ ម៉ិនហុង** ប្រធានការិយាល័យរដ្ឋបាល និងផលិតឯកសារ
ទូរស័ព្ទលេខ ៖ ០១២ ៩៧ ៩១ ៥១

# ឯកសារប្រើសម្រាប់បោះឆ្នោត

## ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧

គ.ជ.ប

**ដើម្បីបោះឆ្នោតបានប្រជាពលរដ្ឋខ្មែរត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត**
**និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត**

បញ្ជីបោះឆ្នោត



+

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ



ឬ

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត






សូមអញ្ជើញប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ទៅបោះឆ្នោតនៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀលឱ្យបានគ្រប់ៗគ្នា !

# គំរូការិយាល័យបោះឆ្នោត និងឯកសារប្រើសម្រាប់បោះឆ្នោត
# ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧

គ.ជ.ប

## គំរូការិយាល័យបោះឆ្នោត ឆ្នាំ២០១៧



## ឯកសារប្រើសម្រាប់បោះឆ្នោត

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ



ឬ



ឬ



ឬ

ឯកសារបញ្ជាក់អត្តសញ្ញាណ សម្រាប់ការបោះឆ្នោត



សូមអញ្ជើញប្រជាពលរដ្ឋខ្មែរទៅបោះឆ្នោតនៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល